# សេចក្តីអំពាវនាវដល់កូនខ្មែរទាំងអស់
# ដែលមានសិទ្ធិបោះឆ្នោត

ដោយសេង ភក្តី (សុភ័ណ)

*ខ្ញុំសូមអំពាវនាវដល់បងប្អូនជនរួមជាតិខ្មែរទាំងអស់ សូមមេត្តាទៅបោះឆ្នោត នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣*

ព្រះពុទ្ធអង្គសំដែងថា សត្វទាំងឡាយ***ទាំងអស់គ្នាកុំបីអាក់ខានឡើយ។*** ការចូលរួមបោះឆ្នោតរបស់អ្នកគឺការចូលរួមធ្វើនយោបាយជីវិតរបស់អ្នក។

## ចុះអ្វីគឺនយោបាយ?

# នយោបាយគឺផ្ទាំងបាយ...

រស់នៅបានដោយអាស្រ័យអាហារ។ ដូច្នេះចូរអ្នកទាំងឡាយចូលរួមបោះឆ្នោតដើម្បីជីវិតធូរធារ ដើម្បីមានការងារធ្វើដែលទទួលបានប្រាក់កំរៃសមរម្យ ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច ប្រកបដោយសមភាពនិងចិរភាព។

# នយោបាយគឺសុខមាលភាពរបស់យើង...

យើងបោះឆ្នោតដើម្បីបានមកនូវសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់យើង។ សុខភាពផ្លូវកាយគឺការមានសេវាកម្មសុខាភិបាលដែលថោកឬមិនគិតថ្លៃ។ សុខភាពផ្លូវចិត្តគឺ ការមានសិទ្ធិសេរីភាពពេញលេញ ក្នុងឋានៈយើងជាសមាជិក

នៃសង្គមប្រជាធិបតេយ្យ ជាពិសេសគឺយើងមានតុលាការនិងសារពត៌មានដែលមានយុត្តិធម៌និងឯករាជ្យ។

# នយោបាយគឺសិទ្ធិសេរីភាព...

ព្រះពុទ្ធអង្គសង្កត់ធ្ងន់ថាសេរីភាពគឺជាគោលដៅខ្ពស់បំផុតរបស់មនុស្សជាតិ ដូច្នេះសេរីភាពបានដល់ការរស់ទៅនូវ ខ្លៅ ឃ្លាន ខ្លាច ហើយចាប់ផ្តើមពង្រឹងនីតិរដ្ឋតាមបែបលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

# នយោបាយគឺអធិបតេយ្យភាពជាតិ...

ចំណុចនេះសំខាន់ណាស់ យើងបោះឆ្នោតដើម្បីការពារអធិបតេយ្យជាតិខ្មែរយើង ហើយយើងរាប់អានបរទេសនិងប្រទេសជិតខាង ក្នុងឋានៈស្មើភាពគ្នា មិនអាចមាននរណាយកប្រៀបលើនរណាបានទេ។

## សូមកុំភ្លេចទៅបោះឆ្នោតទាំងអស់គ្នាដើម្បីការផ្លាស់ប្តូរ *ដែលនាំមកនូវឆ្នាំងបាយ សុខមាលភាព សេរីភាព និងអធិបតេយ្យភាពពិតប្រាកដ* ។